# ការសំភាសន៍របស់បងស្រី លី នើ

កៈ អ្នកសំភាសន៍ រិទ្ធ សុនភានិច្ច ខៈ អ្នកត្រូវបានសំភាសន៍ លី នើ

## <u>ពត៌មានសង្ខេបរបស់បងស្រី លី នើ</u>

បងស្រី លី នើ មានទីលំនៅបច្ចុប្បន្នរស់នៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
គាត់មានបងប្អូន៩នាក់ ហើយគាត់ជាកូនទី៤នកក្នុងគ្រួសារ។ គាត់កើតនៅឆ្នាំ១៩៨៤
ហើយបច្ចុប្បន្នមានកូន៦នាក់។

កៈ
ចឹងថ្ងៃនេះខ្ញុំសូមអរគុណបងស្រីដែលបានផ្ដល់ឳកាសដើម្បីខ្ញុំអាចសំភាសន៍បងនៅក្នុងថ្ងៃនេះចឹងហារ
ហើយការសំភាសន៍របស់យើងត្រូវបានបង្កើតឡើងដោយសកលវិទ្យាល័យមួយនៅក្នុងសហរដ្ឋអាមេរិចដែលគេហៅកាត់ថា BYU
ហើយចឹងគោលបំណងរបស់សកលវិទ្យាល័យយើងគឺដើម្បីថែរក្សាជីវប្រវត្តិរបស់បងសម្រាប់ជូនទៅកាន់កូនចៅជំនាន់ក្រោយរបស់បងដើម្បីពួកគាត់អាចថែរក្សា
ចងចាំអំពីរឿងល្អៗរបស់បងសម្រាប់អនុវត្តន៍ជីវិតប្រចាំថ្ងៃរបស់ពួកគាត់ហើយថ្ងៃនេះគឺយើងហ្នឹងសំភាសន៍នៅភូមិ ភូមិអីគេដែរបង?

ខៈ មិនស្គាល់ទេនៅទីណាទេ ជុំក្នាយ។

កៈ ហ្នឹងហើយនៅភ្នំក្រោមហើយសំភាសន៍ដោយខ្ញុំផ្ទាល់រិទ្ធសុិនស្រីនិច
ហើយចឹងបងស្រីអាចជម្រាបឈ្មោះបងពេញបានទេ?

ខៈ ឈ្មោះខ្ញុំ ឈ្មោះ លី នើ។

កៈ លី នើ អូខេ។

ខៈ ចាស។

កៈ ហើយបងមានឈ្មោះហៅក្រៅពីឈ្មោះហ្នឹងទេ?

ខៈ នើ ហ្នឹងហើយ។

កៈ ចាសមានតែឈ្មោះ១ហ្នឹងទេ ហើយអើបងស្រីអាយុប៉ុន្មាហើយក្នុងឆ្នាំនេះ?

ខៈ ក្នុងឆ្នាំនេះហ្នឹងអាយុ៣៥ឆ្នាំ។

កៈ ៣៥ឆ្នាំ ហើយបងកើតនៅឆ្នាំណាដែរឆ្នាំបារាំងហារ?

ខៈ ៨៤។

កៈ ៨៤ ហើយចុះសម្រាប់ឆ្នាំខ្មែរយើងឆ្នាំមួយណាដែរបង?

ខៈ ឆ្នាំជូត។

កៈ ឆ្នាំជូត ចាសហើយអើបងស្រីដូចជាសម្រាប់បងស្រុកកំណើតរបស់បងនៅណាដែរបង?

ខៈ ស្រុកមេមត់ ខេត្តកំពង់ចាម។

កៈ អ្នកខេត្តកំពង់ចាម។

ខៈ ឥឡូវត្បូងឃ្មុំវិញហើយគេប្តូរ២ឆ្នាំហើយ។

កៈ អូចឹងគេប្តូរពីមេមត់ទៅកំពង់ចាមវិញ។

ខៈ ប្តូរពីកំពង់ចាមទៅត្បូងឃ្មុំ។

កៈ ទៅត្បូងឃ្មុំវិញ ចាសហើយបងនៅទីនោះប៉ុន្មានឆ្នាំដែរ?

ខៈ បាន២០ឆ្នាំជាង ២៤ឆ្នាំ។

កៈ ២៤ឆ្នាំ ចាសចឹងសម្រាប់បងៗមានបងប្អូនប៉ុន្មាននាក់ដែរបង?

ខៈ ទាំងចុងទាំងដើមមាន៩នាក់។

កៈ ៩នាក់ អូហូ បងប្អូនច្រើន។

ខៈ ចាស ម៉ែខ្ញុំមានប្តី៣។

កៈ ហើបងស្រីជាកូនទីប៉ុន្មានក្នុងចំណោមហ្នឹង។

ខៈ ខ្ញុំជាកូនទី៤។

កៈ កូនទី៤ បងអាចរៀបរាប់ឈ្មោះបងប្អូនបងទាំងអស់ហ្នឹងបានហេ?

ខៈ បានតើ ប៉ុន្មានខ្ញុំអត់ស្គាល់នាមត្រកូលបងៗទេ។

កៈ ចាសៗ!

ខៈ បងប្រុសខ្ញុំទី១ឈ្មោះ ចេង ។

កៈ ចាស!

ខៈ បងទី២ឈ្មោះ ចឺ។

កៈ ចាស!

ខៈ បងទី៣ បងស្រីឈ្មោះលី ឡាងឌី។

កៈ លី ឡាងឌី ចាស។

ខៈ ទី៤ខ្ញុំ។

កៈ ទី៣បងស្រី។

ខៈ ប្អូនខ្ញុំ១ទៀត លី ណា។

កៈ លី ណា ចាស។

ខៈ ប្អូនបន្ទាប់១ទៀត សុខ ខឿន។

កៈ ចាស។

ខៈ សុខ ខឿន, សុខ រឿន, សុខ រ៉ា, សុខា។

កៈ ហិហិហិ ឈ្មោះ សុខ រឿន, សុខ ខឿន, សុខ រ៉ា, សុខា ហិហិហិ។

ខៈ ចាស ពៅគេបង្អស់សុខា។

កៈ Ok ចាស ok ហើយមកដល់ពេលនេះតើមានចងចាំសាច់រឿងអ្វីអំពីពួកគាត់ដែរទេ?

ខៈ អឺមបងប្អូនខ្ញុំសុទ្ធតែប្រវត្តិជូរចត់ណាស់និយាយអោយចំទៅ សុទ្ធតែអ្នកបែកគ្នាតាំងពីតូចៗម្ល៉េះ។

កៈ អឺមហឺ។

ខៈ បែកគ្នាចឹងទៅ បងប្រុសខ្ញុំបែកគ្នាទើបតែបានមកជួបជុំគ្នាបានប៉ុន្មាន២ឆ្នាំ៣ឆ្នាំឆ្នាំនេះដែរហ្នឹង។

កៈ អឺមហឺចាស។

ខៈ បងប្រុសខ្ញុំបែកកាលជំនាន់ និយាយចំទៅកាលគាត់នៅក្មេងៗនៅកំលោះបែកគ្នាឡើង១៦-១៧ឆ្នាំ។

កៈ ចាស អូ ចាស!

ខៈ ទើបមកជុំគ្នានៅសៀមរាបវិញ ដើមទីគាត់ៗទៅធ្វើទាហានធ្វើអីគ្រាន់តែប៉ុន្តែគេថាគាត់ស្លាប់អស់ហើយ មុនដំបូងបងប្រុសខ្ញុំហ្នឹងម៉ែខ្ញុំដល់ថ្នាក់ធ្វើបុណ្យហ្នឹងខោអាវទៀតហរ។

កៈ អឺម។

ខៈ បែកបាត់ដំណឹងសូន្យម៉ង ទើបតែគាត់មានកូន៤ទៅជួបម៉ែខ្ញុំនៅកំពង់ចាមវិញបានដឹងថាគាត់នៅរស់។

កៈ ចឹងគាត់ធ្វើបុណ្យគាត់ធ្វើជាឧបកិច្ចហើយៗ។

ខៈ ចាសឧបកិច្ចថាមនុស្សហ្នឹងស្លាប់បាត់ហើយ។

កៈ អឺ!

ខ៖ បើបងខ្ញុំទី១នុះគាត់យកប្រពន្ធនៅភ្នំពេញ
ប្រពន្ធទី១ផិតគាត់ទៅគាត់ទៅយកប្រពន្ធទី២បាត់ដំណឹងឥឡូវមិនទាំងឃើញគាត់ៗស្លាប់បាត់ទៀត។

ក៖អឺមចាស។

ខ៖ ដល់បងស្រីខ្ញុំឈឺនៅក្នុងផ្ទះដល់គាត់ស្លាប់ដែរ។

ក៖ អឺមហឺ។

ខ៖ មិនដែលមានអ្នកណានៅទេ ហើយបើប្អូនៗ...។

ក៖ សព្វថ្ងៃនៅប៉ុន្មាននាក់ដែរបង?

ខ៖ នៅសព្វថ្ងៃនៅ៧នាក់។

ក៖ នៅ ៧នាក់ ហើយនៅពីក្មេងបងទទួលបន្ទុកគ្រួសារច្រើនអត់?

ខ៖ នៅក្នុងបន្ទុកគ្រួសារខ្ញុំទទួលច្រើន ការងារមនុស្សប្រុសទាំងអស់ខ្ញុំធ្វើទាំងអស់។

ក៖ អឺមចាស។

ខ៖ ព្រោះបងប្អូនខ្ញុំ និយាយចំទៅខ្ញុំមានតែ៣នាក់ទេស្រីទាំង៣
បងស្រីខ្ញុំគាត់ឈឺងាប់មួយចំហៀងខ្លួន ប្អូនស្រីបន្ទាប់ពីខ្ញុំហ្នឹងតូច។

ក៖ អឺហឺ។

ខ៖ ដល់ចឹងគ្មានពីណាធ្វើការកើតមានតែខ្ញុំហ្នឹងហើយ។

ក៖ ចាស។

ខ៖ ដងទឹក ដាំបាយ លាងចានអីទៅ។

ក៖ អឺហឺ។

ខ៖ ប៉ុន្មានការងារលាងចានបងស្រីខ្ញុំទោះគាត់ងាប់មួយចំហៀងខ្លួនគាត់ធ្វើ
តែការងារដាំបាយ ពុះអុស រែកទឹករែកអីគឺខ្ញុំទាំងអស់ ការងារធ្ងន់ៗគឺខ្ញុំ។

ក៖ អឺហឺ បងគិតថាស្ថានភាពពេលនុងវាលំបាកខ្លាំងដែរទេសម្រាប់បង?

ខ៖ មិនលំបាកទេ ព្រោះប៉ាខ្ញុំមិនដែលអោយខ្ញុំអត់ស៊ីផង។

ក៖ អឺហឺចាស។

ខ៖ គ្រាន់តែហត់នឿយការងារហ្នឹងប៉ុន្តែខ្ញុំមិនដែលអត់ស៊ី។

ក៖ ចាសៗ។

ខ៖ ព្រោះប៉ាខ្ញុំគាត់អ្នក និយាយចំទៅគាត់អ្នកមធ្យម មានក៏មានថាក្រក៏ក្រ។

កៈ ហិហិហិ ចាស។

ខៈ ព្រោះគាត់កាលគាត់នៅកំលោះគាត់មានកាណូតដូង កាណូតអីគាត់ ។

កៈ អ!

ខៈ
ហើយបងប្អូនគាត់ប្អូនគាត់សុទ្ធតែអ្នកមានចឹងហារបងប្អូនខាងប៉ាខ្ញុំគេសុទ្ធតែអ្នកមាន។

កៈ ចាស។

ខៈ រាល់ថ្ងៃហ្នឹងក៏គេមានដែរប៉ុន្តែគ្រាន់តែខ្ញុំមិនទៅក្បែរគេ។

កៈ ចាស ហើយនៅពេលដែលនៅក្មេងតើបងចូលចិត្តធ្វើអ្វីជាមួយនិងបងប្អូនរបស់បងដែរ?

ខៈ មានធ្វើអីមានតែនៅជួយឌិនខោអាវ កាត់ខោអាវឌិនអី បងស្រីខ្ញុំគាត់ជាងដេរ។

កៈ អ ចាសៗហើយចឹងសម្រាប់បង សម្រាប់ឥឡូវហ្នឹងគឺរស់នៅផ្សេងៗគ្នាមែនទេបង?

ខៈ ចាសរស់នៅបែកគ្នា ឥឡូវហ្នឹងមកលេងផ្ទះបង។

កៈ ចាស ok ហើយសម្រាប់ម្តាយរបស់បងគាត់មានឈ្មោះអ្វីដែលបង?

ខៈ ឈ្មោះ ខុម សូត្រ ខុម។

កៈ សូត្រ ខុម ចាសចុះលោកឪពុកវិញបង?

ខ. លោកឪពុកខ្ញុំឈ្មោះ លី សុខឡេង។

កៈ លី សុខឡេង ហើយអីសព្វថ្ងៃពួកគាត់នៅទាំង២មែនទេ?

ខៈ ប៉ាខ្ញុំគាត់ខូចតាំង៥-៦ឆ្នាំហើយ។

កៈ អឺម។

ខៈ នៅម្តាយ ម្តាយនៅឈឺរាំរ៉ៃនៅផ្ទះ។។

កៈ ម្តាយឈ្មោះអ្វីដែរ អូអាយុប៉ុន្មានហើយសព្វថ្ងៃ?

ខៈ ម៉ែខ្ញុំអាយុ ៥០ជាង។

កៈ អឺហឺចាស។

ខៈ ៥៦-៥៧។

កៈ ចាស ចុះបងដឹងថាពួកគាត់កើតនៅក្នុងឆ្នាំណាដែរទេ?

ខៈ អត់ដឹងទេ គ្រានតែដឹងថាឆ្នាំគាត់បើសិនជាកាលគាត់នៅរស់អាយុចូល៩០ហើយ។

កៈ អឺហឺ។

ខៈ ដឹងតែឆ្នាំខ្មែរ ឆ្នាំខ្មែរម៉ែខ្ញុំគាត់កើតឆ្នាំរកា លោកប៉ាខ្ញុំឆ្នាំនេះឆ្នាំឆ្លូវ។

កៈ អឺមចាសៗ។

ខៈ អត់ដឹងថាខ្ញុំណាទេ គ្រាន់តែថាឆ្នាំបារាំងយើងអត់ដឹង យើងនៅតូចៗ។

កៈ អឺហឺ ចាស
ហើយចុះសម្រាប់មកទល់ពេលនេះតើអឺចង់និយាយថាពួកគាត់រស់នៅក្នុងកំពង់ចាមដដែរឬក៏ម៉េចដែរ?

ខៈ រស់នៅកំពង់ចាមដដែរ។

កៈ ចាស ស្រុកកំណើតគាត់នៅហ្នឹងផ្ទាល់មែនទេ?

ខៈ ចាស ស្រុកកំណើតគាត់នៅហ្នឹងផ្ទាល់។

កៈ ចាស
ហើដូចជាពួកគាត់ដែលធ្លាប់និយាយរឿងរ៉ាវការពីពួកគាត់នៅក្មេងនិយាយប្រាប់បងទេ។

ខៈ កាលប្រវត្តិម៉ែខ្ញុំនៅក្មេង និយាយចំទៅខ្ញុំបែកម៉ែខ្ញុំតាំងពីខ្ញុំអាយុ៥ឆ្នាំហើយ។

កៈ អឺហឺចាស!

ខៈ រហូតដល់ខ្ញុំមានកូនមានចៅហើយបានទៅនៅជាមួយគាត់វិញ។

កៈ ចាស!

ខៈ ប៉ុន្តែបើជំនាន់ប៉ាខ្ញុំគាត់ធ្លាប់ប្រាប់ថាកាលពីគាត់នៅកំលោះគាត់ថៅកែកាណូតដ។

កៈ អឺហឺ។

ខៈ ថៅកែកាណូតដនៅចាហែ។

កៈ ចាស។

ខៈ ប៉ុន្តែគ្រាន់តែគាត់អ្នក
និយាយចំគាត់សមដែរប៉ុន្តែបើថាអោយគាត់មានគាត់អត់បានមានទេព្រោះគាត់ត្រូវការចិញ្ចឹមប្អូន។

កៈ អឺហឺ។

ខៈ
លឺតែគាត់និយាយចឹងប៉ុន្តែបើដើមទីគាត់និយាយចំទៅគាត់តាំងពីខ្ញុំស្គាល់ខ្ញុំដឹងក្តីមកខ្ញុំដឹងថាគាត់នៅធ្វើការនៅកន្លែងរោងចក្រអារឈើ។

កៈ ចាស!

ខៈ គាត់បងថៅកែរោងចក្រអារឈើ។

ក៖ អឺហឺចាស។

ខ៖ ដឹងតែប៉ុណ្ណឹង ប៉ុន្តែកាលខ្ញុំមិនទាន់ដឹងក្តីគាត់ធ្វើអ្វីៗយើងអត់ដឹង។

ក៖ ចាសៗ!

ខ៖ កាលជំនាន់ពល ពត គាត់ធ្វើអ្វីខ្ញុំអត់ដឹងដែរ ប៉ុន្តែកាលជំនាន់ពល ពត គ្រាន់តែដឹងថាគាត់ធ្លាប់មានប្រពន្ធដើមនៅគ្រួយប្រសិទ្ធ។

ក៖ អូចាស។

ខ៖ កំពង់ចាម ប៉ុន្តែប្រពន្ធហើយនិងកូនគាត់ស្លាប់បាត់ហើយ។

ក៖ អឺហឺ!

ខ៖ ជំនាន់ពល ពត នុះ ។

ក៖ ចាស!

ខ៖ បានដឹងតែប៉ុណ្ណឹង។

ក៖ ចាស ហើយប៉ារបស់បងគាត់ជាមនុស្សបែបណាដែរ?

ខ៖ គាត់មានបែបណា គាត់អត់មានអ្វីទេ។

ក៖ ចង់ថាកាច ស្លូតអីចឹងហារ?

ខ៖ កាចក៏មិនកាច ស្លូតក៏មិនស្លូត មធ្យមកណ្តាល។

ក៖ ហិហិហិ។

ខ៖ បើថាកូនខុសគាត់វៃ បើថាកូនមិនខុសគាត់អត់វៃ។

ក៖ ចាសៗ

ខ៖ គឺចឹងហើយម៉ែខ្ញុំក៏ចឹងដែរ ប៉ុន្តែម៉ែខ្ញុំម៉ាត់គាត់និយាយចំទៅម៉ាត់...។

ក៖ ម៉ាត់ឆៅហេ ហិហិហិ។

ខ៖ ម៉ាតម៉ែអាឆៅ ប៉ុន្តែគាត់ថាស្តីអស់ហើយ។

ក៖ ចាស។

ខ៖ ញាតិចូលផ្ទះគាត់មួយណាក៏ញាតិទាំងអស់ គាត់អត់ដែលរាប់សត្រូវទេ។

ក៖ ចាស។

ខ៖ ប៉ុន្តែគ្រាន់តែថាម៉ាត់គាត់ៗឃើញម៉េចគាត់ថាចឹង។

ក៖ ហ្នឹងហើយ។

ខ៖ ដេរៗម៉ង ថាៗម៉ង។។

ក៖ គាត់និយាយត្រង់ៗ។

ខ៖ ប៉ុន្តែគ្រាន់តែថាញាតិមួយណាក៏អត់ចោលគាត់ដែរ។

ក៖ ចាស អឺហឺហើយឪពុកបងគាត់គឺជាអ្វីគេបង អ្នកជួលកាណូតហេ? គាត់ធ្វើអ្វីដែរ។

ខ៖ កាលពីដើមអ្នករត់កាណូតដ។

ក៖ ចាស។

ខ៖ គាត់ថៅកែកាណូតដ ប៉ុន្តែនិយាយចំទៅតាំងពីខ្ញុំស្គាល់ដឹងក្តីមកគឺគាត់មិនដែលនៅគាត់លុយ គាត់ចាស់មែន ប៉ុន្តែគាត់មិនដែលអាវអត់សុំទានមិនស្មើហ្នឹងគាត់ផង ខោអាវគាត់គគ្រិចប៉ុន្តែគាត់តែនៅក្នុងហោប៉ៅគាត់អត់អោយកូនដាច់។

ក៖ ហិហិហិ។

ខ៖ មានតិចបំផុតក៏៣០-៤០ម៉ឺន នោះថ្ងៃគាត់ស្លាប់នុះក្នុងខោអាវគាត់នុះនៅចោលក្នុងធុងសម្រាមមន្ទីរពេទ្យក៏បោះចោលឡើងអស់៣០ម៉ឺនជាង។

ក៖ អូហរចាស។

ខ៖ គាត់អាណិត។

ក៖ ចាស។

ខ៖ បងប្អូនគាត់ប្អូនគាត់និយាយចំទៅគាត់មាន។

ក៖ អឺហឺ។

ខ៖ បងប្អូនប៉ាខ្ញុំនិយាយចំគាត់ប្អូនបន្ទាប់ពីប៉ាខ្ញុំទី២ហ្នឹងគាត់ថៅកែរោងចក្រទឹកកកឡើង៥-៦កន្លែង។

ក៖ ចាស។

ខ៖ ហើយគេៗអ្នកធ្វើថ្នល់ធ្វើអីហ្នឹងគេមាននិយាយចំទៅម៉ាប្រចាំកំពង់ចាមគេមានម៉ង។

ក៖ អឺហឺ។

ខ៖ ហើយបើប្អូនគាត់ពៅគេវិញកូនៗសុទ្ធតែអ្នកបកប្រែនៅភ្នំពេញ។

ក៖ អឺហឺចាស។

ខ៖ គេសុទ្ធតែអ្នកមានៗអត់តែខ្ញុំ១ទេ អត់តែបងប្អូនខ្ញុំតែ២នាក់ ទាស់តែឪពុកស្លាប់ហ្នឹងនិយាយអោយចំទៅព្រោះខ្ញុំអត់ទៅរកគេ

បើទៅរកគេយើងចេះតែទៅរកបានតែយើងខ្លួនក្បាលកញ្ចាស់ប៉ុណ្ណឹងហើយមិនដឹងទៅរកគេធ្វើម៉េច ខ្ជិល។

ក៖ អឺហិហិ។

ខ៖ សុទ្ធចិត្តដើរអត់ស៊ីមានស៊ីខ្លួនឯង មានប្ដីមានប្រពន្ធខ្លួនឯងទៅ។

ក៖ ចាសហើយអីគាត់ដែលអីហ្នឹងហើយចាស
ហើយចុះម្ដាយបងគាត់ធ្វើអ្វីដើម្បីចិញ្ចឹមជីវិតដែរពេលគាត់នៅពីក្មេងៗអូដូចជាពេលបងនៅពីក្មេងៗចឹងហារ។

ខ៖ គាត់និយាយចំទៅគាត់កាលខ្ញុំនៅក្មេងៗជំទន់ៗគាត់ខាង អង្គការសិទ្ធនារី។

ក៖ អូចាស។

ខ៖ ឥឡូវហ្នឹងគាត់គាត់ធ្វើអនុយុំ។

ក៖ អនុឃុំម្ដង ហិហិហិ។

ខ៖ ចាស គាត់ធ្វើអនុឃុំគ្រាន់ថាគាត់អត់បានធំ។

ក៖ ចាស។

ខ៖ គាត់បានត្រឹមចិញ្ចឹមជំងឺគាត់ដែរសព្វថ្ងៃហ្នឹងបើជំងឺគាត់ឡើង៣-៤មុខនុះ បេះដូងចំហរដំបៅបេះដូងផង ហើយឈាមកកក្នុងបេះដូងផង។

ក៖ អឺសុទ្ធតែបេះដូង។

ខ៖ ហើយខួរឆ្អឹងគាត់អត់មានទេ។

ក៖ អឺហឺ។

ខ៖ គាត់អស់ហើយ អស់ខួរឆ្អឹងហើយពេទ្យគេហាមអត់អោយដួលទេ។

ក៖ អឺហឺហើយសព្វថ្ងៃសុខភាពគាត់ទន់ខ្សោយមែនទេបង?

ខ៖ ចាស ទន់ខ្សោយបានប្អូនខ្ញុំអាបន្ទាប់ពៅចិញ្ចឹមមើលថែរាល់ថ្ងៃច័ន្ទ។

ក៖ គាតអាចដើរអាចធ្វើដំណើរបាន?

ខ៖
ដើរបានអីបានធ្វើការធម្មតាតិចតួចអីបានប៉ុន្មានគ្រាន់តែអោយគាត់ខឹងអីគាត់តែតែហត់ ហើយអោយតែធ្វើការធ្ងន់ក៏គេអត់អោយធ្វើ
ព្រោះឆ្អឹងគាត់និយាយអោយចំទៅអស់ខួរអាលួងហើយ វាពុកអស់ហើយពុកឆ្អឹងអស់ហើយ។

ក៖ ចាស។

ខ៖ ចឹងគេអត់អោយធ្វើការធ្ងន់ទេ។

ក៖ អឺហឺ។

ខ៖ និយាយចំទៅសុំខមាទោស និយាយចំទៅចាំតែថ្ងៃទេ។

ក៖ អឺហឺ ប៉ុន្តែគាត់នៅមានកូនបងនៅចាំមើលថែរក្សាគាត់។

ខ៖ ចាស។

ក៖ ចាស សម្រាប់ជីដូនជីតារបស់បងវិញតើបងនៅចងចាំឈ្មោះតាយាយរបស់បងដែរទេ?

ខ៖ ចាំតែខាងម្ដាយខាងឪពុកអត់ដែរចាំទេ។

ក៖ ចាស។

ខ៖ ព្រោះខ្ញុំកើតអត់ទាន់ ខាងម្ដាយខ្ញុំគាត់ឈ្មោះ សូត្រ ធម៌, សូត្រ ខុម។

ក៖ ចាស។

ខ៖ គាត់ខាងម្ដាយឈ្មោះ សូត្រ។

ក៖ ចាស

ខ៖ ខាងតាអត់ចាំដែរចាំតែខាងយាយ។។

ក៖ ចាំតែខាងយាយ

ខ៖ ចាំតែម្នាក់ហ្នឹង។។

ក៖ ហើយបងដឹងថាពួកគាត់រស់នៅណាអត់?

ខ៖ គាត់នៅកំពង់ចាម។

ក៖ កំពង់ចាមដែរ។

ខ៖ ចាស បងប៉ាខ្ញុំខាងជីតាគាត់នៅខាងចាហែ
ចាហែខាងកំពង់ចាមដែរគ្រាន់តែថា១នៅខាងគោក ១នៅខាងទន្លេ។

ក៖ ចាស អូចឹងខាងបងហ្នឹងប៉ាបងគឺនៅខាងទន្លេ។

ខ៖ ចាស ប៉ុន្តែស្រុកកំណើតខ្ញុំកើតជានៅកំពង់ចាម ស្រុកមេមត់ខាងគោក។

ក៖ ចាស Ok ហើយបងដែលរកនៅជាមួយលោកយាយរបស់បងដែលបងចាំឈ្មោះហ្នឹងដែរទេ?

ខ៖ អត់ដែរទេ អត់ដែរឃើញមុខគាត់ផង។

ក៖ អ ចាស។

ខ៖ និយាយអោយចំទៅទាំងខាងឪពុកខាងម្ដាយ យាយគឺអត់ដែលឃើញមុខទាំងអស់។

ក៖ អឺហឺចាស។

ខ៖ ឃើញតែរូបថត រូបថតហ្នឹងថតឃើញមិនច្បាស់ទៀត គឺបានប៉ុន្មានដងឥឡូវអស់ទៀត

ក៖ ចាស ហើយគាត់ដែរធ្លាប់និយាយរឿងរ៉ាវប្រាប់បងហេ?

ខ៖ អត់ដែរទេ បើបងប្រុសខ្ញុំបានគាត់ដឹង គាត់ធំជាងខ្ញុំ គាត់ទាន់យាយខ្ញុំ។

ក៖ ចាស។

ខ៖ ប៉ុន្តែបើខ្ញុំអត់ទាន់ទេ ខាងយាយទាំងសងខាង ខាងតាទាំងសងខាងគឺអត់ទាន់ទាំង២

ក៖ ចាស ហើយក្រុមគ្រួសារបងនៅពីរស់នៅកំពង់ចាមនិងសៀមរាបតើគាត់មានទៅរស់នៅណាផ្សេងដែរទេបង?

ខ៖ អត់ដែរមានទេ។

ក៖ អឺហឺ។

ខ៖ មានតែនៅខាងនុងអត់មានអ្នកណាដែលដើរចេញក្រៅទេ។

ក៖ ចុះដូចជាក្រៅប្រទេសអត់មានដែរ។

ខ៖ បើបងជីដូនមួយខ្ញុំមានក្រៅប្រទេស។

ក៖ គាត់ទៅនៅណាដែរបង?

ខ៖ នៅអូស្រ្តាលី។

ក៖ អូស្រ្តាលី ហើយគាត់ដែលមកលេងស្រុកទេ។

ខ៖ ដែរតើ កាលប្រពន្ធការនៅស្រុកគាត់ដែរ គាត់កើតនៅភ្នំពេញ បងជីដូនមួយខ្ញុំនៅភ្នំពេញ ហើយបងជីដូនមួយនៅភ្នំពេញនៅកំពង់ចាម។

ក៖ ចាស!

ខ៖ ហើយបងប្អូនជីដូនមួយនៅកំពង់ចាមក៏ធ្លាប់នៅស្រុកក្រៅដែរប៉ុន្តែយើងអត់ដឹងគេនៅស្រុកណា ប៉ុន្តែគ្រាន់ថាយើងអត់ដឹង។

ក៖ ចាស!

ខ៖ និយាយអោយចំទៅយើងអត់ដែរទៅគេ ប៉ុន្តែបងដែលនៅអូស្រ្តាលីហ្នឹងបងធ្លាប់ទៅការគាត់បាននៅរស់ហ្នឹងធ្លាប់ទៅការគាត់។

ក៖ ចាស!

ខ៖ ទៅការគាត់នៅភ្នំពេញ។

ក៖ ហើយសម្រាប់ចូលមកឈានមកអាពាពិពាហ៍បងវិញ ស្វាមីបងឈ្មោះអ្វីដែរបង?

ខៈ ខ្ញុំដូចមិនចាំទេ។

កៈ ហិហិហិ សព្វថ្ងៃ។

ខៈ សព្វថ្ងៃអើខ្ញុំមិនចង់រំលឹកទេបើទៅចោលថ្ងៃ៣ខែ៤ខែ ប្តីខ្ញុំរាល់ថ្ងៃហ្នឹងគេឈ្មោះ ចាន់

កៈ ចាស ហើយបងរៀបអាពាពិពាហ៍នៅឆ្នាំណាដែរ?

ខៈ ខ្ញុំមិនទាន់បាន និយាយចំទៅសែនជាមួយគ្នាមិនទាន់បាន២ឆ្នាំៗនេះផង
បើប្តីខ្ញុំមុនខ្ញុំយកបានយូរប៉ុន្តែឥឡូវវាទៅរកប្រពន្ធចុងទៀតហើយ។

កៈ ចឹងសម្រាប់បងវិញបងគាត់បានចោលស្ត្រីដណ្តឹងបងទេ។

ខៈ ស្រឡាញ់ចិត្តនិងចិត្ត!

កៈ អឺហឺ ស្រឡាញ់ចិត្តនិងចិត្តជាមួយគ្នា
ហើយបងអាចប្រាប់ពីដំណាក់កាលដំបូងដែលបងបានជួបជាមួយស្វាមីបងដែរទេ?

ខៈ ជួបគ្នាដំបូងតាមទូរស័ព្ទ!

កៈ អូ ស្គាល់គ្នាតាមទូរស័ព្ទ!

ខៈ តាមទូរស័ព្ទដំបូងស្គាល់គ្នានិយាយចំទៅពួកម៉ាកគេត្រូវបងធម៌ខ្ញុំ!

កៈ ចាស!

ខៈ ហើយចឹងទៅគេយកលេងអោយគ្នាទៅវិញទៅមកចឹងទៅ
ក៏ស្គាល់គ្នាស្គាល់គ្នាហ្នឹងក៏ខ្ញុំថាមិនយកដែរប៉ុន្តែគ្រាន់ថាគេសែនយើងយើងយកទៅ
បាយសម្លអីទៅវត្តចឹងទៅ ដំបូងថាអត់យកដល់ចុងក្រោយ ដល់ចុងក្រោយក៏ចឹងទៅ!

កៈ អឺហឺ ចុះបងមានកូនប៉ុន្មានហើយ?

ខៈ កូនខ្ញុំ៦ហើយ!

កៈ ៦ហរ!

ខៈ ចាស!

កៈ បងអាចរៀបរ៉ាប់ឈ្មោះគាត់បានទេ?

ខៈ អូខ្ជិលរៀបរ៉ាប់ណាស់កូនគាត់ទៅខាងគេអស់ហើយនៅជាប់តែក្នុងខ្លួន១ទេ។

កៈ ចាសមានតែ១ក្នុងពោះ។

ខៈ ១ក្នុងពោះហ្នឹងក៏មិនចង់ទុកទៀតទេ កុំអោយជាប់ពូជ។

កៈ អឺមបងហរ។

ខៈ មែនខ្ញុំអត់ចង់ទុកអោយជាប់ពូជទេ។

ក៖ ចាស!

ខ៖ ចាំមើលតែថ្ងៃឆ្លងទន្លេបើគេមកយកក៏ទុកអោយគេទៅ
បើគេមកបំរើក៏អោយគេទៀតទៅ ព្រោះធ្វើអោយយើងឆ្អែតដំកពេក។

ក៖ ចាស សម្រាប់បងខ្សែជីវិតបងរបស់ដល់បងចាប់ធំឡើងរហូតដល់សព្វថ្ងៃនេះ
ហើយបងរៀនដល់ថ្នាក់ទីប៉ុន្មានដែរ?

ខ៖ បានថ្នាក់ទី៥។

ក៖ បានថ្នាក់ទី៥។

ខ៖ ខ្ញុំអ្នកអត់ចេះអក្សរទេ ចេះតែលេខ។

ក៖ ចេះតែលេខ ពូកែលេខ បងៗអាចសរសេរអក្សរខ្មែរបានហេ?

ខ៖ និយាយសូមទោស បើថាអោយសរសេរតាមខ្ញុំក្រែងលោសរសេរខុសអក្សរទៀត
អត់ចេះទេ។

ក៖ ចុះអានវិញបង។

ខ៖ អានក៏មិនចេះដែរ។

ក៖ អានក៏មិនចេះដែរ ចុះក្រៅពីភាសាខ្មែរតើបងចេះភាសាអ្វីផ្សេងទេ?

ខ៖ អ្វីក៏អត់ចេះដែរ។

ក៖ អត់ចេះដែរ។

ខ៖ ចិនចេះបានមួយម៉ាត់ៗ

ក៖ ចេះចិនមួយម៉ាត់ៗ

ខ៖ ចាស។

ក៖ ចាស។

ខ៖ ចាស ហៅហារ ដាក់ប៊ុង អីចឹងទៅព្រោះធ្លាប់ទៅនៅផ្ទះឪពុកធម៌ចេះចិន។

ក៖ ចាស ok ចុះសម្រាប់បងសាលារៀនដែលបងរៀនកាលហ្នឹងសាលារៀនអ្វីដែរបង?

ខ៖ សាលាបឋមហ៊ុនសែនប៊ុនរ៉ានីមេមត់។

ក៖ ចាស ហើយចម្ងាយផ្លូវពីផ្ទះបងទៅសាលាប្រហែលជាចម្ងាយប៉ុន្មាន?

ខ៖ ប្រហែលជា 100ម៉ែត្រ។

ក៖ ហិហិហិ ជិតហ្នឹង។

ខ៖ ចាស ឆ្លងថ្នល់ដល់។

ក៖ ចាសដើរមួយភ្លាតដល់ ហើយបងមានមិត្តភក្រ្តដែលរស់នៅអូ
ដែលធំធាត់មកជាមួយគ្នាដល់សព្វថ្ងៃទេ?

ខ៖ មានៗច្រើនណាស់ ប្អូនធម៌ក៏មាន ពួកម៉ាកក៏មាន។

ក៖ ចាស ok ហើយសម្រាប់បងៗចាំអនុស្សាវរីយ៍ជាមួយពួកគាត់ហេ?

ខ៖ ចាំ ចាំមិនភ្លេចទេប្អូនធម៌។

ក៖ ចាស ឥឡូវសូមអោយបងចែកចាយបន្តិចបន្តួច។

ខ៖ អើ អនុស្សាវរីយ៍ពួកខ្ញុំគ្រង់តែដើរលេងបុណ្យភូមិ។

ក៖ ហិហិហិ។

ខ៖ អូបុណ្យភូមិណាក៏ដល់ដែរ!

ក៖ ចាស!

ខ៖ អោយតែថារាំ។

ក៖ ចូលចិត្តរាំមែនទេបង?

ខ៖ រាំហើយហ្នឹងវៃគ្នា។

ក៖ ហិហិហិ ចាស
ហើយតាំងពីបងនៅក្មេងរហូតដល់ឥឡូវតើជីវិតបងមានការផ្លាស់ប្តូរអ្វីខ្លះដែរ?

ខ៖ ផ្លាស់ប្តូរឆ្ងាយណាស់ តាំងពីប៉ានៅរស់រហូតដល់ប៉ាស្លាប់ ប៉ាខ្ញុំនៅរស់ខ្ញុំមិនដែលលំបាកទេ
ប៉ុន្តែពេលប៉ាស្លាប់ទៅខ្ញុំលំបាក ដូចថាយើងយកប្តី១ណាក៏ដូចថាមិនដូចចិត្តចឹងហារ
ប្រវត្តិកំសត់ជាមួយប្តីនិយាយអោយចំទៅ។

ក៖ ចាស!

ខ៖ ប្រវត្តិខ្ញុំនិយាយអោយចំទៅ ពេលគេឈឺយើងមើលថែ ពេលយើងឈឺគេរត់ចោលបាន។

ក៖ តែអ្វីដែលជា ដែលជាកំលាំងចិត្តដែលជំរុញអោយបងតស៊ូរហូតដល់សព្វថ្ងៃ
ថាជំរុញចិត្តខ្ញុំខ្ញុំថាបើនិយាយចំទៅខំថាបើគ្មានម្នាក់ហ្នឹងក៏ខ្ញុំអាចរស់បាន។

ក៖ ចាស!

ខ៖ ព្រោះខ្ញុំៗត្រូវការមើលប្អូនខ្ញុំបន្តទៀត
ព្រោះប្អូនខ្ញុំមាននៅជាប់ជាមួយម៉ែខ្ញុំនៅជាមួយខ្ញុំមួយដែរ។

ក៖ ចាស!

ខ៖ ចឹងខ្ញុំទោះបើប្តីខ្ញុំគេទៅបាត់ក៏ខ្ញុំនៅមានសង្ឃឹមចិត្តខ្ញុំថាខ្ញុំនៅត្រូវតែរស់។

ក៖ ចាសចឹង។

ខៈ មិនខ្វះទេអ្នកយកយើងតទៀត ហើយមិនខ្វះទេញាតិយើងមាន
យើងកើតមកក៏មិនមែនយើងយកប្តីមកដែលយើងយកបងប្អូនមកតើ។

កៈ ចាស ត្រឹមត្រូវ។

ខៈ ម៉ែឪបង្កើតមកចឹងហើយខ្ញុំអត់ត្រូវការខូចចិត្ត។

កៈ ចឹងវាជាកំលាំងចិត្តរបស់បងមែនទេ?

ខៈ ចាស!

កៈ ល្អមែនទែន ខ្ញុំចូលចិត្តអ្វីដែលបងនិយាយ ហិហិហិ ok
ចឹងអីសម្រាប់បងឆាកជីវិតរបស់បងបានធ្វើការអ្វីខ្លះដែរ?

ខៈ អូការងារមិនខ្វះទេការងារនុះ កញ្ចះគេមិនខ្វះចឹងម៉ង។

កៈ ហិហិហិ ធ្លាប់ធ្វើអ្វីខ្លះដែរបង?

ខៈ ស៊ីឈ្នួលមើលកូនគេក៏មាន ទៅថៃក៏មាន។

កៈ ចាស អូទៅនៅប្រទេសថៃទៀត។

ខៈ ចាស!

កៈ ហើយអត់ចេះថៃទេបងហេ?

ខៈ អត់ទេបើគេនិយាយមកស្តាប់បាន ។

កៈ អូ!

ខៈ តែយើងបកមកវិញយើងរឹងម៉ាត់ យើងអត់ចេះ។

កៈ ចាស យើងអាចស្តាប់បាន។

ខៈ ចាស ចង់គេជេរម៉េចក៏ដឹងដែរ ប៉ុន្តែគ្រាន់ថាយើងនិយាយទៅវិញយើងអត់ចេះ
យើងៗរឹងអណ្តាត។

កៈ ចាស ហ្នឹងហើយលំបាកចាស។

ខៈ យើងនិយាយអត់ចេញ។

កៈ ហើយធ្វើអ្វីទៀតដែរបង?

ខៈ ដើរស៊ីឈ្នួលគេនិយាយចំទៅតាមនឹកឃើញទៅណា អាគេអោយទៅមើលកូនគេ
គេអត់អោយធ្វើអ្វីទេ
គេអោយទៅមើលកូនគេអាទៅដល់ភ្លាមគេភ្ជួតឯងថាម៉ាស៊ីនបោកខោអាវខូច
បោកខោលីអូទាំងនាមម៉េចក៏ឃើញដែរ។

កៈ អឺហឺ!

កៈ ចាស!

ខៈ ខ្ញុំគេចង់ទូលម៉េចក៏មិនជឿដែរ។

កៈ ចាស ឆ្លងកាត់រយៈពេល ទោះបីអាយុប៉ុណ្ណឹងប៉ុន្តែបងឆ្លងកាត់បញ្ហាច្រើន។

ខៈ បញ្ហាច្រើនណាស់ខ្ញុំហរ និយាយចំទៅមិនទាន់ស្គាល់ជាតិមានទេ។

កៈ ចាស!

ខៈ បើក្រស្គាល់អស់ហើយ។

កៈ ចាស!

ខៈ រហាមក៏ស្គាល់ដែល ស៊ីឈ្នួលគេជានិច្ចជាកាលអីឃើញហើយ។

កៈ ចាស ហើយសម្រាប់បងតើម្ហូបឬក៏ល្បែងអ្វីដែលបងចូលចិត្តលេងកំសាន្តចឹងហារ?

ខៈ និយាយចំល្បែងលេងកំសាន្តចូលចិត្តរាំ។

កៈ អឺហឺចាស។

ខៈ រាំចង់ម៉ូតម៉េចក៏បានដែរ។

កៈ ហិហិហិ ចូលចិត្តមែនទេបង?

ខៈ ចាស!

កៈ ចុះមុខម្ហូបវិញ?

ខៈ មុខម្ហូប និយាយចំទៅអ្វីក៏អត់តម។

កៈ ចាស ញ៉ាំបានទាំងអស់។

ខៈ ចាស ព្រោះអីយើងធ្លាប់ យើងធ្លាប់អត់
យើងកន្លែងតែរើសម្ហូបយើងទៅធ្វើខ្ញុំគេយើងបានអីហូប។

កៈ ចាស!

ខៈ ចឹងស្អីក៏ហូបបានដែរ អំបិលម្ទេសក៏ហូបបាន។

កៈ ហិហិហិ ត្រូវ ហិហិហិ ហើយចម្រៀងអ្វីដែលបងចេះតាំងពីក្មេងរហូតដល់ពេលនេះដែរបង?

ខៈ អត់ចេះទេអាចម្រៀងហ្នឹង ប៉ុន្តែបើថាអោយស្តាប់គេច្រៀងៗចេញ
ប៉ុន្តែបើអោយច្រើនខ្លួនឯងអត់ចេញ។

កៈ ចាស!

ខៈ ប៉ុន្តែម៉ាចេញ
ម៉ាកាលម៉ារីករៀនចេះតែបទពីដើមតែមួយបទគត់ប៉ុន្តែមិនដឹងថាពីណាអ្នកច្រៀង។

ក៖ បទអ្វីគេបង។

ខ៖ កាច់ផ្ការំចង់។

ក៖ អ!

ខ៖ ប៉ុន្តែមិនដឹងពីណាអ្នកច្រៀង។

ក៖ ចាស!

ខ៖ ចេះតែមួយបទហ្នឹង ថ្នាក់ទី១ដល់ទី៥គ្រូអោយប្រឡងឡើងច្រៀងៗតែបងហ្នឹង។

ក៖ ហិហិហិ ស្រឡាញ់បទហ្នឹងហេបងហេ?

ខ៖ និយាយចំទៅចេះតែមួយបទហ្នឹង។

ក៖ អូចាស Ok
ចុះសម្រាប់គ្រួសារបងវិញនៅក្នុងគ្រួសារបងតើមានអ្នកណាគេចេះលេងឧបករណ៍ភ្លេងបុរាណភ្លេចសម័យអីទេបង?

ខ៖ ដូចអត់មានពីណាគេចេះទេ។

ក៖ អឺហឺ អត់មានពីណាគេចេះទេ។

ខ៖ ចាស!

ក៖ ហើយផ្ទះបងមានលក្ខណៈយ៉ាងម៉េចដែរពីក្មេងរហូតដល់បច្ចុប្បន្ន។

ខ៖
និយាយអោយចំទៅពីក្មេងរហូតដល់បច្ចុប្បន្ននិយាយអោយចំទៅតាំងពីបែកពីប្តីហ្នឹងទៅលំបាក ប៉ុន្តែបើថាកាលនៅក្នុងបន្ទុកគ្រួសារជាមួយឪពុកក៏អត់ដែលលំបាក។

ក៖ ចាស!

ខ៖ គាត់អត់ដែលលំបាក ត្រីមិនដែលស៊ីត្រីតូច និយាយមែន
ស្លិនមែនតែអាមួយគីឡូកន្លះទៅមួយគីឡូ
និយាយមែនត្រីកុំថាត្រីរៀលត្រីចង្វាគឺអត់ដែលស៊ីតែម្តងនៅជាមួយឪពុក។

ក៖ ចាស!

ខ៖ តែដល់ចាប់ផ្តើមយកប្តីគឺវេទនាម៉ង យើងនៅជាមួយម៉ែឪអត់អី។

ក៖ ចាស!

ខ៖ និយាយចំម៉ែឪខ្ញុំ ឪខ្ញុំក៏ចឹងទៅគាត់ដែលមានទៅអត់អីគាត់
បើបងប្អូនគាត់សុទ្ធតែរោងចក្រទឹកកកប៉ុណ្ណាណីគេចិញ្ចឹមគាត់ ចឹងអត់ដែលអត់ទេ។

ក៖ បងសម្រាប់បងៗដែលចេះសាងសង់ធ្វើផ្ទះខ្ទមតូចៗអីចេះធ្វើដែរទេ។

ខ៖ ចេះ!

ក៖ អឺហឺ!

ខ៖ រោងប៉ុណ្ណេះបើសិនអោយខ្ញុំធ្វើមានឈើអត់លំបាកទេម្នាក់ឯង។

ក៖ ចាសដោយសារខ្ញុំបានស្តាប់បងថាបងអាចធ្វើការងារប្រុសៗក៏បានដែរចឹងហារ។

ខ៖ ហិហិហិ និយាយចំទៅធ្វើការជាមួយប្តីខ្ញុំអាចាន់រាល់ថ្ងៃហ្នឹង ប្តីខ្ញុំធ្វើរោងអត់ចេញផងហ្នឹង ខ្ញុំអ្នកធ្វើខ្លួនឯង។

ក៖ អូ ហិហិហិ ចាស ហើយបងសម្រាប់បងចេះធ្វើ
សម្រាប់សាងសង់ផ្ទះហ្នឹងចេះធ្វើពីអ្នកណាគេដែរអ្នកណាគេបង្រៀន?

ខ៖ និយាយចំទៅ យើងធ្លាប់ដើរចឹងទៅ យើងធ្លាប់មើលចឹងទៅ យើងចេះខ្លួនឯង។

ក៖ អូចេះធ្វើខ្លួនឯង ។

ខ៖ និយាយចំទៅយើងដំដើងម៉ាអី
យើងធ្វើអីនិយាយចំទៅយើងធ្វើកូនប្រុសចឹងហើយការងារហ្នឹងយើងត្រូវតែចេះ
ដើរជួសជុលដំបូលផ្ទះអីត្រូវជំនាញខ្ញុំហ្នឹងហើយអ្នកចេះ។

ក៖ ចាស។

ខ៖ ចឹងហើយបើយើងមិនចេះមានអ្នកណាហ្នឹងធ្វើ គាគាត់ចាស់ងងឹត
បងស្រីគាត់ខ្វិនដៃខ្វិនជើង ប្អូនក៏តូច ចឹងមិនខ្ញុំទាំងអស់។

ក៖ អឺហឺ។

ខ៖ វែជញ្ជាំងផ្ទះជញ្ជាំងអីហ្នឹងយើងហ្នឹងឯង។

ក៖ ចាស។

ខ៖ ជួសជុលផ្ទះតិចតួចអី តអំពូលភ្លើងតអី យើងហ្នឹងឯង។

ក៖ បងអ្នកធ្វើ?

ខ៖ ហ្នឹងហើយ។

ក៖ ហើយបងមានជំនាញអ្វីផ្ទាល់ខ្លួនដែលបងចេះពីគ្រួសារបងហេ?

ខ៖ ជំនាញខ្ញុំអត់ចេះអីទេ។

ក៖ ហិហិហិ។

ខ៖
ព្រោះនិយាយចំទៅតាំងពីតូចដល់ធំយើងចេះនិយាយចំទៅចេះតែជំនាញចិត្តខ្លួនឯងចង់ធ្វើ
។

ក៖ អឺហឺ។

ខ៖ បើថាជំនាញខាងម៉ែខាងឪគឺអត់ដែលមានទេ។

ក៖ ចាស។

ខ៖ ព្រោះម៉ែខ្ញុំ អូនិយាយចំទៅម្ដាយខ្ញុំគាត់ខាងភ្លេង។

ក៖ ចាស។

ខ៖ ភ្លេងខ្មែរខាងល្ខោនបាសាក់។

ក៖ អូ ចាស។

ខ៖ ម៉ែគាត់អ្នកលេងល្ខោនកាលពីគាត់នៅក្រមុំ។

ក៖ អឺហឺគាត់ចេះធ្វើ។

ខ៖ ចាស។

ក៖ តែដល់ពេលដល់បងៗអត់ចេះ ហិហិហិ។

ខ៖ ហិហិហិ មកដល់ខ្ញុំៗខាងសម័យ។

ក៖ ហិហិហិ។

ខ៖ ចេះខាងរាំ។

ក៖ ចាស
ហើយបងអាចប្រាប់ខ្ញុំអំពីទុក្ខលំបាកនៅក្នុងជីវិតរបស់បងដែលបងចាំមិនដែលភ្លេច
លំបាកខ្លាំងហាររហូតដល់សព្វថ្ងៃបងចាំ ដូចជាចាំអត់ដែលភ្លេចបានទេ?

ខ៖ កាលដែលលំបាក។

ក៖ អឺហឺ។

ខ៖ ចាំខ្លាំងបំផុត លំបាកជាងគេគឺបងវៃ។

ក៖ ហិហិហិ។

ខ៖ មែនបងខ្ញុំវៃខ្ញុំជាងគេជាមួយប្ដីខ្ញុំ ។

ក៖ អឺហឺ។

ខ៖ និយាយចំទៅលំបាកតែបងវៃតែមួយមុខគត់។

ក៖ ចាស។

ខ៖ បើចំពោះឪពុកៗមិនដែលវៃទេ ឪពុកខ្ញុំវៃម្ដងដែលកាលម៉ាហឺកនៅចាហែ ទាត់ខ្ញុំ៣ជើង
ទាត់មិនមែនទាត់តែខ្ញុំទេទាត់ទាំងប្អូនខ្ញុំមីមួយនិងទាត់ខ្ញុំមួយទៀត

កន្លែងអោយហៅមីប្អូនត្រូវឡើងកាណូតដងៗចេញម៉ោង ត្រូវម៉ោងគាត់ចេញចឹងហារ ដល់ហើយចឹងទៅពេលយើងមកផ្ទះហ្នឹង អត់មកទេកន្លែងតែជក់មើលរឿងនៅហាងកាហ្វេ ដល់កន្លែងតែជក់មើលនៅហាងកាហ្វេពុកវៃ
វៃហើយនំទាំងថាសប៉ុណ្ណេះគាត់ទិញពីចិនមកមកអោយខ្ញុំស៊ីទាំងអស់។

កៈ ហិហិហិ វៃហើយអោយនំញ៉ាំទៀត។

ខៈ វៃហើយអោយនំញ៉ាំ។

កៈ ហិហិហិ។

ខៈ ចឹងហើយអត់មានលំបាកទេ បើលំបាកៗជាមួយបង។

កៈ ចាស។

ខៈ តាំងខ្ញុំស្គាល់ដឹងក្ដីអាយុ១៣-១៤មក លំបាកជាមួយបង បងស្រី។

កៈ អឺហឺ។

ខៈ បងស្រីខ្ញុំនិយាយចំទៅស្អប់ខ្ញុំ។

កៈ អឺហឺចាស។

ខៈ មិនដឹងគាត់គិតម៉េចជាមួយខ្ញុំ វៃខ្ញុំសុទ្ធតែចងស្លាបសេក ចងសំបុកស្រមោច ជួនកាលទៅអោយដេកក្រៅផ្ទះ។

កៈ អឺហឺ ចុះបងដូចជាសម្រាប់អឺបទពិសោធន៍ល្អៗដែលបងចងចាំមានទេ?

ខៈ បទពិសោធន៍ល្អៗដែលខ្ញុំចងចាំពេលនៅជាមួយម៉ែពុក។

កៈ អឺហឺ។

ខៈ
ទោះម៉ែពុកខ្ញុំគាត់ទៅចោលខ្ញុំមែនតែខ្ញុំនៅមានប្រវត្តិល្អៗខ្ញុំនៅចាំដូចថាខ្ញុំមិនភ្លេចគុណគាត់។

កៈ ចាស។

ខៈ ខ្ញុំមិនភ្លេចគុណម្ដាយខ្ញុំត្រង់ម៉េច ត្រង់គាត់ពរពោះខ្ញុំ
គាត់ទៅបាត់ដោយសារគាត់លំបាកខ្លាំងបានគាត់ទៅចោលខ្ញុំ។

កៈ អឺហឺ។

ខៈ ប៉ុន្ដែឪពុកខ្ញុំផលល្អគាត់ច្រើន។

កៈ អឺ។

ខៈ ខ្ញុំរាប់អត់អស់ទេ។

កៈ ចឹងបងមានក្តីស្រឡាញ់ពីឪពុកម្តាយច្រើន។

ខៈ ខ្ញុំមានក្តីស្រឡាញ់ពីឪពុកច្រើន។

កៈ ចាស។

ខៈ ម្តាយខ្ញុំម្តាយខ្ញុំក្តីស្រឡាញ់មិនសូវមានទេ។

កៈ អឺហឹ។

ខៈ នៅតែខ្ញុំស្រឡាញ់គាត់ បើថាក្តីស្រឡាញ់មកខ្ញុំកម្រណាស់។

កៈ ចាស ប៉ុន្តែឪពុកបងបានផ្តល់ច្រើន។

ខៈ ចាស បើឪពុកខ្ញុំ១០០ភាគ១០០០។

កៈ ចាស ok
ចឹងសម្រាប់ពេលនៅក្មេងតើបងសង្ឃឹមថាចង់ធ្វើអ្វីទេពេលដែលបងធំឡើងហារ?

ខៈ
កាលនៅពីក្មេងនិយាយចំទៅចិត្តចង់ទៅរាំនៅប៉ុស្តិ៍ប៉ុន្តែគ្រាន់ថាយើងវាអត់មានលទ្ធផលហ្នឹងទៅ។

កៈ អូ ចង់ធ្វើជា Dance ចង់ធ្វើជាអ្នករាំ។

ខៈ ចាស!

កៈ ចាស Ok
ហើយចឹងសម្រាប់ចុងក្រោយតើបងមានអ្វីផ្តែផ្តាំសម្រាប់សារខ្លីៗជាចុងក្រោយសម្រាប់កូនបងទីចឹង។

ខៈ ខ្ញុំបើកូនខ្ញុំ បើសារចុងក្រោយខ្ញុំមិនមានអីទេ
ខ្ញុំមានតែថាអោយវាតែខំរៀនខំសូត្រអីទៅ។អោយវាតែម៉េចម៉េឪគ្មានអ្វីចែកអោយទេមានតែការរៀនហ្នឹងចែកអោយ។

កៈ ចាស ចំណេះវិជ្ជា។

ខៈ យើងដូចថាថ្ងៃក្រោយកុំអោយយកគំរូខុស យកតែគំរូត្រូវដាក់ខ្លួនទៅបានហើយ។

កៈ ចាស!

ខៈ តែប៉ុណ្ណឹង។

កៈ ចាស ok
ចឹងខ្ញុំក៏អត់មានអ្វីសួរបងដែលចឹងហីដូចជាយើងសួរសំនួរចុងក្រោយមួយទៀតថាតើបងអនុញ្ញាតអោយខ្ញុំធ្វើការដាក់រូបថតហើយនិងសំឡេងរបស់បងទៅក្នុង Website BYU យើងបានទេបង?

ខៈ បានខ្ញុំអត់ឃាត់ទេ ព្រោះអ្នកទាំងអស់គ្នាមកធ្វើបែបនេះគឺមានន័យថាចង់សុំតែប៉ុណ្ណឹង។

កៈ ចាស ហិហិហិ។

ខៈ អត់ឃាត់ ព្រោះខ្ញុំនិយាយចំថតទៅមានយកទៅធ្វើអ្វីផង។

កៈ ចាស។

ខៈ ព្រោះខ្ញុំអត់មានអ្នកលួចគេលួចអីផង ខ្ញុំអត់មានអីត្រូវខ្លាចអីអោយផ្សាយ។

កៈ ចាសៗអរគុណច្រើនបង។

ខៈ ហើយរឿងខ្ញុំសោះខ្ញុំមិននិយាយរឿងគេផង។

កៈ Ok
ចឹងបទសំភាសន៍យើងគឺត្រូវបានបញ្ចប់អរគុណបងមែនទែនសម្រាប់ការផ្ដល់បទសំ។ភាសន៍ល្អៗសម្រាប់ថ្ងៃនេះ។

ខៈ ចាសៗ។

កៈ អរគុណច្រើនបង។

ខៈ អរគុណ ។